ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០១៥ ......សហវ.គណ.ណ.ស.ទ.១០.ថ

# សេចក្តីណែនាំ
# ស្តីពី
# នីតិវិធីនៃការស្នើសុំឥណទាន និងការស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែម

អនុលោមតាមមាត្រា ៦៨ មាត្រា ៦៩ មាត្រា ៧៣ និងមាត្រា ៧៤ នៃច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣, អនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម និងប្រកាសលេខ ៥៧៦ សហវ.ប្រក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីយន្តការបង្វិលសងអាករលើតម្លៃបន្ថែម និងក្នុងគោលបំណងពង្រឹងការអនុវត្តយន្តការអាករលើតម្លៃបន្ថែមឱ្យមានប្រសិទ្ធភាព តម្លាភាព និងស័ក្តិសិទ្ធិភាព ជាពិសេសផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធក្នុងការស្នើសុំឥណទាន ឬស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែម **(អតប)** ឱ្យបានឆាប់រហ័ស ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំ ដូចខាងក្រោម៖

## ១. នីតិវិធីនៃការស្នើសុំឥណទានអាករលើតម្លៃបន្ថែម

ដើម្បីស្នើសុំឥណទានអតប អ្នកជាប់ពន្ធមធ្យមឬអ្នកជាប់ពន្ធធំ ត្រូវអនុវត្តដូចខាងក្រោម៖

ក- ត្រូវស្នើសុំឥណទានអតប តាមរយៈការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធអាជីវកម្មប្រចាំខែតាមអនឡាញ (E-Filing) របស់អគ្គនាយកដ្ឋានពន្ធដារ **(អពដ)**។

ខ- ត្រូវស្នើសុំឥណទានអាករលើធាតុចូលក្នុងខែ ដែលទទួលបានការផ្គត់ផ្គង់ក្នុងស្រុក ឬការនាំចូលទំនិញដោយបុគ្គលជាប់អតបក្នុងខែប៉ុណ្ណោះ។

គ- ឥណទានអតបត្រូវបានអនុញ្ញាតចំពោះតែការផ្គត់ផ្គង់ជាប់អតប ឬការនាំចូល សម្រាប់ប្រើប្រាស់ដើម្បីធ្វើការផ្គត់ផ្គង់ជាប់អតបប៉ុណ្ណោះ។ ដោយឡែក ចំពោះអ្នកជាប់ពន្ធដែលមានសកម្មភាពអាជីវកម្មផ្គត់ផ្គង់មិនជាប់អាករ មិនអាចស្នើសុំឥណទានអាករលើធាតុចូលបានឡើយ។

ឃ- ឯកសារភស្តុតាងសម្រាប់ការស្នើសុំឥណទានអតប មានជាអាទិ៍៖

- ចំពោះការទិញទំនិញ ឬសេវាក្នុងស្រុក អ្នកជាប់ពន្ធត្រូវមានវិក្កយបត្រអាករ(ច្បាប់ដើម)ដែលមាននិទ្ទេសត្រឹមត្រូវ ដូចមានចែងក្នុងប្រកាសលេខ ៧២៣ សហវ.ប្រក ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ ស្តីពីវិធាននៃការប្រើប្រាស់វិក្កយបត្រ ដោយមិនអនុញ្ញាតឱ្យជាឥណទានអតបឡើយ ចំពោះវិក្កយបត្រធម្មតា (Commercial Invoice)
- ចំពោះការនាំចូល អ្នកជាប់ពន្ធត្រូវមានប្រតិវេទន៍គយ និងបង្កាន់ដៃបង់ប្រាក់(ច្បាប់ដើម) ដែលមានបញ្ជាក់អំពីឈ្មោះ និងព័ត៌មានត្រឹមត្រូវរបស់សហគ្រាសស្នើសុំ។

## ២. នីតិវិធីនៃការស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែម

ដើម្បីធានាឱ្យការបង្វិលសងអតបប្រព្រឹត្តទៅបានឆាប់រហ័ស មានតម្លាភាព និងធានាការទូទាត់ថវិកាបង្វិលសងបានទាន់ពេលវេលា ស្របតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ អ្នកជាប់ពន្ធមធ្យមឬអ្នកជាប់ពន្ធធំដែលស្នើសុំបង្វិលសងអតប ត្រូវអនុវត្តដូចខាងក្រោម៖

ក- អ្នកជាប់ពន្ធដែលមានការនាំចេញជាសំខាន់ ឬចុះបញ្ជីជាសហគ្រាសវិនិយោគដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងបុគ្គលជាប់អាករដទៃទៀត ដែលមានឥណទានអាករលើធាតុចូលលើស ចាប់ពី ៣ ខែ ជាប់គ្នា

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

ឡើងទៅ អាចធ្វើការស្នើសុំបង្វិលសងអតប ដោយត្រូវបោះពុម្ពពាក្យស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែម តាមប្រព័ន្ធ E-Filing។ ដើម្បីទទួលបានការបង្វិលសងឆាប់រហ័ស អ្នកជាប់ពន្ធដែលមានឥណទានអាករលើធាតុចូលលើសអាករលើធាតុចេញ អាចធ្វើការស្នើសុំបង្វិលសង ក្នុងរយៈពេល **៣ខែ ឬ៦ខែ ឬយ៉ាងយូរ ១ឆ្នាំ** ដោយចៀសវាងការរក្សាទុកឥណទានអតបយោងបង្គរច្រើនឆ្នាំ ដែលធ្វើឱ្យបង្កើនបន្ទុកដល់រដ្ឋបាលសារពើពន្ធ និងចំណាយពេលវេលាយូរក្នុងការពិនិត្យផ្ទៀងផ្ទាត់វិក្កយបត្រនិងឯកសារពាក់ព័ន្ធនានា។ ក្នុងករណីអ្នកជាប់ពន្ធបង្គរទុកឥណទានអាករលើធាតុចូលមិនបានស្នើសុំបង្វិលសងលើសពី១ឆ្នាំ រយៈពេលបង្វិលសងដូចមានចែងក្នុងប្រកាសលេខ ៥៧៦ សហវ.ប្រក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីយន្តការបង្វិលសងអាករលើតម្លៃបន្ថែម នឹងពុំត្រូវបានអនុវត្តឡើយ។

ខ- ការបង្វិលសងមិនត្រូវបានអនុញ្ញាតផ្តល់ជូនទេ ក្នុងករណីអ្នកជាប់ពន្ធបង្គរឥណទានអាករលើធាតុចូលលើសពីរយៈពេល ៣ ឆ្នាំ (N-3)។ ដោយឡែក ចំពោះឥណទានអាករលើធាតុចូលដែលមិនទាន់ស្នើសុំបង្វិលសងពីឆ្នាំមុនៗកន្លងមក (មុនឆ្នាំ២០២០) អ្នកជាប់ពន្ធត្រូវដាក់លិខិតស្នើសុំបង្វិលសងមក **អពជ** មិនត្រូវឱ្យហួសពីដំណាច់ឆ្នាំ២០២៣ នេះឡើយ ពុំនោះទេការបង្វិលសងនឹងមិនត្រូវបានផ្តល់ជូនឡើយ។ ម្យ៉ាងទៀត ការបង្វិលសងអតបត្រូវបានអនុញ្ញាតផ្តល់ជូនចំពោះតែឥណទានអាករលើធាតុចូលទាំងឡាយណាដែលមានឯកសារភ័ស្តុតាងគាំទ្រ និងទិន្នន័យនៃការប្រកាសបង់ពន្ធរបស់អ្នកផ្គត់ផ្គង់ត្រឹមត្រូវ។

គ- ត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានគណនីធនាគារ និងព័ត៌មានសហគ្រាសឱ្យបានត្រឹមត្រូវនិងទាន់ពេលវេលា។

ឃ- ត្រូវផ្តល់ឯកសារ និងបញ្ជីគណនេយ្យអាករលើតម្លៃបន្ថែម តាមការតម្រូវនានាឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលាកំណត់របស់ **អពជ** ពុំនោះទេការស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែមនឹងត្រូវបានព្យួរទុក ឬបដិសេធ រហូតដល់ថ្ងៃដែល **អពជ** បានទទួលឯកសារ និងបញ្ជីទាំងនោះ។

ង- **អពជ** អាចធ្វើការព្យួរទុកការបង្វិលសងអតបជាបណ្តោះអាសន្ន ក្នុងករណីសហគ្រាសណាមួយស្នើសុំបង្វិលសងមានជាប់ជំពាក់បំណុលពន្ធ ឬបានទទួលរងនូវការកំណត់ពន្ធឡើងវិញ រហូតសហគ្រាសនោះបានដោះស្រាយបំណុលពន្ធ ឬចូលខ្លួនមកដោះស្រាយការកំណត់ពន្ធឡើងវិញរួចរាល់។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សង្ឃឹមយ៉ាងមុតមាំថា គ្រប់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ដែលធ្វើសកម្មភាពសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា នឹងយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃ.................. ខែ.................. ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ សីហា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន ៖**

-អគ្គនាយកដ្ឋានពន្ធដារ

"ដើម្បីមុខការ"

-សភាពាណិជ្ជកម្មកម្ពុជា

"ដើម្បីចូលរួមផ្សព្វផ្សាយ"

-ស្ថានបេសកកម្មរបស់ប្រទេសនានាតាំងនៅព្រះរាជាណាចក្រកម្ពុជា

-ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់ប្រទេសនានា

-អង្គការអន្តរជាតិនានាតាំងនៅព្រះរាជាណាចក្រកម្ពុជា

"ដើម្បីជូនជ្រាប"

-ឯកសារ-កាលប្បវត្តិ